## Receiving/welcoming visitors and paying visits to others



### ជប់លៀងនៅផ្ទះសុភាព

សុភាព៖ អូ វណ្ណា! ម៉ោហើយអេ៎? ចូលម៉ោ។
វណ្ណា៖ មានអ្នកណាម៉ោខ្លះនៅ?
សុភាព៖ ម៉ោពីរបីនាក់ហើយ។ យកអីញ៉ាំសិនទៅណា។ ខ្ញុំទៅរៀបចំតិចសិន។
វណ្ណា៖ អត់អីទេ សុភាពរវល់ចុះ។

### មកលេងផ្ទះដោយមិនប្រាប់មុន

សុភាព៖ អូ វណ្ណា! ម៉េចម៉ោអត់ប្រាប់មុនអីចឹង? ចូលម៉ោសិនម៉ោ។
វណ្ណា៖ ខ្ញុំម៉ោជួបភ្ញៀវនៅជិតហ្នឹង ហើយក៏ឈោងចូលលេងសុភាពឯងទៅ។ សុភាពមានត្រូវទៅណាអត់?
សុភាព៖ ងៃនេះខ្ញុំទំនេរតាស។ អត់មានត្រូវទៅណាផង។ វណ្ណាឯងសុខសប្បាយអេ៎? ចាំតិច ខ្ញុំទៅយកទឹកម៉ោឲ្យសិនណា។
វណ្ណា៖ មិនបាច់ទឹកអីទេសុភាព។ ខ្ញុំអង្គុយតែម៉ាភ្លែតដែរទេ។

| | |
|---|---|
| សុភាព / វណ្ណា | male or female / male Cambodian names |
| ម៉ោ | spoken form of មក |
| អេ៎ | spoken form of the question or negation particle ទេ |
| រវល់ចុះ | you can get busy (implying: don’t worry about me) |
| ប្រាប់មុន | to inform in advance |
| ឈោងចូលលេង | to drop by/in |
| ងៃ | spoken form of ថ្ងៃ |
| អង្គុយ | here: to stay |
| ម៉ាភ្លែត | ម៉ា is the spoken form មួយ |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

នៅខ្មែរ ការទៅលេងផ្ទះនរណាម្នាក់ដោយមិនប្រាប់មុនមិនមែនជាការខុសឆ្គងអ្វីនោះទេ។ ប៉ុន្តែ ដើម្បីកុំឲ្យទៅខក ឬ ពិបាកដល់ម្ចាស់ផ្ទះ គេគួរតែទូរស័ព្ទទៅសួរម្ចាស់ផ្ទះជាមុនសិន។ នៅពេលមានភ្ញៀវមកលេង ម្ចាស់ផ្ទះគួរទទួលដោយលើកទឹកឬភេសជ្ជៈផ្សេងៗមកជូនភ្ញៀវ ប្រសិនបើចំម៉ោងបាយ គួរហៅភ្ញៀវពិសាបាយជាការគួរសម។

| | |
|---|---|
| ខុសឆ្គង | wrong, awkward |
| ទៅខក | to go “for nothing” |
| ពិបាកដល់ | to cause trouble for |
| ប្រសិនបើចំម៉ោងបាយ | if it’s just meal time |

## Additional dialogue

វណ្ណា៖ អាឡូ សុភាព! ខ្ញុំវណ្ណាអ៊ា។ ង៉ៃហ្នឹង សុភាពទំនេរអេ៎? ខ្ញុំចង់ទៅជួបនិយាយតិច។
សុភាព៖ ទំនេរតាស។ វណ្ណាចង់មោម៉ោងម៉ាន? ហើយមានរឿងអីអ៎?
វណ្ណា៖ ចាំជួបគ្នាចាំនិយាយ។ ម៉ោងដប់អីខ្ញុំទៅដល់។ ម៉េចដែរ?
សុភាព៖ មានអី បានតាស។ មកដល់ចុចកណ្ដឹងម៉ោណា។
...
វណ្ណា៖ អីចឹង ខ្ញុំគិតរកទៅវិញហើយណា សុភាព។ អរគុណច្រើន។
សុភាព៖ នៅញ៉ាំបាយសិនអីវណ្ណា?
វណ្ណា៖ អត់អីទេ ខ្ញុំមានណាត់បន្ទាប់ពីហ្នឹង។

| | |
|---|---|
| អ៊ា | emphatic particle |
| ... តិច | makes a request softer |
| ម៉ាន | spoken form of ប៉ុន្មាន |
| អ៎ | particle used to form a yes/no question similar to ឬ |
| ចាំជួបគ្នាចាំនិយាយ | I’ll tell you when we meet |
| មានអី | ok/alright |
| ចុចកណ្ដឹង | to ring the bell |
| គិតរក | [I’m] thinking of |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.